# ការងារស្ទូច យោង

## (1) ការងារស្ទូច

មានតែអ្នកដែលមានជំនាញនិងយល់ដឹងពីបន្ទុកលើកប៉ុណ្ណោះ ទើបអាចប្រតិបត្តិការរថយន្តស្ទូចចល័តបាន។




## (សមត្ថភាពចាំបាច់)

| | បណ្ណអនុញ្ញាត | វគ្គបណ្តុះបណ្តាលជំនាញ | ការបណ្តុះបណ្តាលពិសេស |
|---|---|---|---|
| ប្រតិបត្តិការរថយន្តស្ទូចចល័តដែលមានបន្ទុកលើក 5 តោន ឬច្រើនជាងនេះ | ○ | | |
| ប្រតិបត្តិការរថយន្តស្ទូចចល័តដែលមានបន្ទុកលើក 1 តោន ឬច្រើនជាងនេះ ឬតិចជាង 5 តោន | ○ | ○ | |
| ប្រតិបត្តិការរថយន្តស្ទូចចល័តដែលបន្ទុកលើកតិចជាង 1 តោន | ○ | ○ | ○ |

## (2) ពន្លួតជើងជ្រែងឲ្យអស់




**បញ្ហាដែលត្រូវអនុវត្ត**

1. ត្រូវតែក្រាលទ្រាប់ដីត្រង់កន្លែងទម្លាក់ជើងជ្រែង។
2. ជើងជ្រែងគួរតែពន្លួតឲ្យអស់។
3. ចូរយកចិត្តទុកដាក់ចំពោះកាំប្រតិបត្តិការនៅពេលបត់។
4. ហាមលើកបន្ទុកនៅចំហៀងរថយន្ត ចូរលើកនៅចំហៀងខាងក្រោយរថយន្តវិញ។

# (3) ហាមចូលទៅក្រោមបន្ទុកស្ទូចនៅពេលកំពុងស្ទូច



## បញ្ហាដែលត្រូវអនុវត្ត

1. ហាមបុគ្គលិកចូលក្រោមបន្ទុកស្ទូច។
2. ចូរប្រាកដថាមិនចូលទៅក្រោមបន្ទុកស្ទូចនៅពេលស្ទូចលើកនិងទម្លាក់ចុះ។
3. ប្រសិនបើគិតថាអាចមានគ្រោះថ្នាក់ដោយសារតែខ្យល់ខ្លាំង ។ល។ ចូរផ្អាកការងារសិន។

## (4) ចូរយកចិត្តទុកដាក់ចំពោះតំបន់ការងារនៅពេលបត់។

នៅពេលផ្ទុក/ទម្លាក់បន្ទុកចុះដោយប្រើប៉ែលចូកឬសន្ទូចរថយន្ត ។ល។
ហាមស្ថិតនៅក្នុងកាំបត់។



### បញ្ហាដែលត្រូវអនុវត្ត

1. ហាមស្ថិតនៅក្នុងកាំប្រតិបត្តិការ។
2. ចូររៀបចំផ្លូវសុវត្ថិភាព។

## (5) ជំនាញសម្រាប់ការងារស្លូចយោង

ចាំបាច់ត្រូវមានជំនាញខាងក្រោមនេះនៅពេលអនុវត្តការងារស្លូចយោង។

| | វគ្គបណ្តុះបណ្តាលជំនាញ | ការបណ្តុះបណ្តាលពិសេស |
|---|---|---|
| ប្រតិបត្តិការរថយន្តស្ទូចចល័តដែលមានបន្ទុកលើក 1 តោន ឬលើសនេះ | ○ | |
| ប្រតិបត្តិការរថយន្តស្ទូចចល័តដែលមានបន្ទុកលើកតិចជាង 1 តោន | ○ | ○ |



**បន្ទុកលើក**

1 តោន ឬលើសនេះ
អ្នកដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ

តាមជាង 1 តោនឬច្រើនជាងនេះ
អ្នកដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលពិសេស

* "**បន្ទុកលើក**" មិនមែនជាទម្ងន់នៃបន្ទុកលើកទេ
ប៉ុន្តែវាជាបន្ទុកលើករបស់ដងសន្ទូចឬរថយន្តស្ទូចចល័ត។

# (6) យុទ្ធនាការ 3-3-3 សម្រាប់ការងារស្ទូចលើក

## បំពេញការងារលើកឌីណាមិក យុទ្ធនាការ 3-3-3




## បញ្ហាដែលត្រូវអនុវត្ត

1. លើកផុតបាន 30 ស.ម ចូរពិនិត្យមើលលំនឹងបន្ទុកលើក។
2. ផ្អាក់បន្ទុកលើក 3 វិនាទី ដើម្បីពិនិត្យមើលស្ថានភាពខ្សែព្រយុង។
3. អ្នកបញ្ជាស្ទូចគួរស្ថិតនៅចម្ងាយ 3 ម៉ែត្រពីបន្ទុកលើកខណៈពេលកំពុងលើក។

## (7) ហាមប្រើខ្សែពួរប្រភេទទាំងនេះ




ហាមប្រើខ្សែពួរដូចខាងក្រោមនេះៗ

1. ខ្សែដែកកំពិតឬស្តួច ។
2. វិមាត្រខ្សែថយចុះលើសពី 7% នៃវិមាត្រដើមរបស់វា ។
3. ខ្សែដែលមានស្នាមខ្ទួញ ។
4. សរសៃខ្សែចំនួន 10% ឬច្រើនជាងនេះដាច់ក្នុងមួយស្រទាប់ខ្សែ ។
5. ខ្សែដែលកម្រងភ្នែកថ្លក់ធូរលុង ។
6. ខ្សែដែលមានដាច់សោត់ត្រង់ភ្នែកស្រោប ។

# (8) ការងារស្ទូចយោង





នៅពេលស្ទូចបន្ទុកដោយប្រើខ្សែពីរនិង
ព្យាយាមលើកវា។



ដោយគិតថាបន្ទុកលើកមិនមានលំនឹងនិងគ្រោះថ្នាក់
ឈប់ស្ទូច ប៉ុន្តែបាច់ក្តារបានរបូតខ្សែ ហើយប៉ះជនរគ្រោះ។